៤- គណៈកម្មការនាំមុខ តា ប៉ាវ CIRAD

៥- គណៈកម្មការនាំមុខ រតនគិរី

គណៈកម្មការជាតិ មានសិទ្ធិបង្កើតក្រុមការងាររបស់ខ្លួន ដែលមានសមាស-ភាព មកពីក្រសួងស្ថាប័ន ពាក់ព័ន្ធ ដើម្បីជាជំនួយការងារ ។

មាត្រា ៤ : សមាជិកគណៈកម្មការជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៥ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម អស់លោកដែលមានឈ្មោះ ក្នុងមាត្រា ១ ត្រូវទទួល អនុវត្តតាមអនុក្រឹត្យនេះចាប់ពី ថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និងត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

*ភ្នំពេញថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៩*

**អនុក្រឹត្យ លេខ ៥៣ អនក្រ**

**ស្តីពីការផ្ទេរនិយ័តភាពជមិកា ឆ្នាំ ១៩៩៩ របស់**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ពីជំពូក ១០**

**និង ជំពូក ៣១ មកបំពេញឲ្យជំពូក ១១**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី ដែលប្រកាស ឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជ-ក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យ លេខ ០១ អនក្រ ចុះថ្ងៃទី ០៥ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែក ឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤
-តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន អភិវឌ្ឍន៍ជនបទ

**សំរេច**

មាត្រា ១ : អនុញ្ញាតឲ្យធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤ របស់រដ្ឋលេខាធិការដ្ឋាន អភិវឌ្ឍន៍ជនបទ ចំនួន ២២០.០០០.០០០ រ ០០ ( ពីរយម្ភៃលានរៀលគត់ ) ពី: ជំពូក ១០ : ២០០.០០០.០០០រ០០ ( ពីរយលានរៀលគត់ ) ជំពូក ៣១ : ២០.០០០.០០០រ០០ ( ម្ភៃលានរៀលគត់ ) បញ្ចូលទៅក្នុងជំពូក ១១

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ ហ៊ុន សែន

* * *